01239059

E402

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-May-2016, 08:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

**សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បីរៀបចំសម្រាប់ការពិនិត្យសាក្សី ស ២១ ដែលនៅសល់ ដើម្បីការពារដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI

**ចម្លងជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្តីផ្តើម

១. អនុលោមតាម មាត្រា៣៣ និង៣៥ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ (ចាប់ពីពេលនេះហៅថា "ច្បាប់បង្កើត អវតក") វិធាន៨៥ នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") សហមេធាវីការពារក្តី លោក នួន ជា ("មេធាវីការពារក្តី") ស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យពន្យារពេលបួនសប្តាហ៍ ដើម្បីឲ្យមេធាវីការពារក្តីរៀបចំឲ្យបានសមរម្យសម្រាប់ការសួរដេញដោលសាក្សីស២១ ដែលនៅសេសសល់-ក្រៅពីសាក្សី 2-TCW-8080[1]។ មេធាវីការពារក្តីយល់ឃើញថា ពេលវេលាបន្ថែម គឺចាំបាច់សម្រាប់ឲ្យមេធាវីការពារក្តីអាចរៀបចំសួរដេញដោលសាក្សី 2-TCW-906, 2TCW-816 និង 2TCW-916 ("សាក្សីស២១ ដែលនៅសេសសល់) អនុលោមតាមការវិវឌ្ឍន៍ថ្មីៗនេះនៅក្នុងសំណុំរឿង និងចំនួនឯកសារដែលត្រូវពិនិត្យឡើងវិញ ដើម្បីរៀបចំការសួរដេញដោលសាក្សីទាំងនេះ ។ មេធាវីការពារក្តីយល់ឃើញថា ការពន្យារពេលគឺចាំបាច់ដើម្បីការពារសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់ សិទ្ធិរបស់គាត់ដើម្បីសួរដេញដោលសាក្សី និងដើម្បីធានាសមភាពនៃមធ្យោបាយនៃការតទល់ក្តី ។

២. ខណៈដែលមេធាវីការពារក្តីបានព្យាយាមអស់ពីសមត្ថភាពរបស់ខ្លួនដើម្បីដោះស្រាយល្បឿននៃការជំនុំជម្រះ អនុលោមតាមការបន្ថែមនាពេលថ្មីនូវឯកសារជាច្រើននៅក្នុងសំណុំរឿង-ជាពិសេសបញ្ជីអ្នកទោសរបស់ កសចស-និងចំនួនឯកសារដែលពាក់ព័ន្ធនឹងសាក្សី 2-TCW-906, 2TCW-816 និង 2TCW-916 ធ្វើឲ្យមេធាវីការពារក្តីគ្មានជម្រើសអ្វីក្រៅពីសុំពេលវេលាបន្ថែមដើម្បីរៀបចំ និងដើម្បីធានាថា ផលប្រយោជន៍របស់លោក នួន ជា ត្រូវបានការពារយ៉ាងត្រឹមត្រូវ ។

## II. ច្បាប់ជាធរមាន

៣. អង្គជំនុំជម្រះសាលាដំបូងរបស់ អវតក ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលមានចែងនៅក្នុង មាត្រា ១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ

[1] ភស្តុតាងរំពឹងទុកពីសាក្សី 2-TCW-8080 មានវិសាលភាពកម្រិតទាក់ទងនឹងស២១ ជាងសាក្សីដែលនៅសេសសល់ ហើយហេតុដូច្នេះមេធាវីការពារក្តីអាចរៀបចំការសួរដេញដោលរូបគាត់ដោយមិនចាំបាច់នូវពេលវេលាបន្ថែមឡើយ ។

('ICCPR')[2] ។ម្យ៉ាងទៀតអនុសញ្ញា ICCPR បានបញ្ចូលជាច្បាប់កម្ពុជា តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដូច្នេះវាជាច្បាប់កម្ពុជា ។

---

[2] មាត្រា ៣៣ថ្មី នៃច្បាប់ អវតក ។ មាត្រា ១៤ នៃអនុសញ្ញា ICCPR ចែងថា: "១. ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថភាព ឯករាជ្យ និងមិនលំអៀងដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងរឿងព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងរឿងក្តីរដ្ឋប្បវេណី។ សារព័ត៌មាន និងសាធារណៈជន អាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកមួយណាសវនាការ សម្រាប់ផលប្រយោជន៍នៃទំនៀមទំលាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់ភាគីតម្រូវឲ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់បំផុត តាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេសដែលថាការធ្វើជាសាធារណៈនឹងឲ្យខូចប្រយោជន៍យុត្តិធម៌។ ប៉ុន្តែការចេញសាលដីការទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី ត្រូវប្រកាសជាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ ។ ២. ជនដែលត្រូវចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់តាមច្បាប់ ។ ៣. ក្នុងការសម្រេចការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងនឹងខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម: (ក)ត្រូវបានព័ត៌មានភ្លាមៗ និងដោយអំលិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។ (ខ)ត្រូវមានពេលវេលា និងសម្ភារៈគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។ (គ)ត្រូវបានជំនុំជម្រះដោយឥតពន្យារពេល ។ (ឃ)ត្រូវជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬ តាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួនការច្បាប់ ហើយត្រូវបានទទួលជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយលើជំនួយការច្បាប់ (ង) ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរសម្លើយ ក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដោះបន្ទុកដែរ។ (ច)ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតបង់ថ្លៃ បើជនជាប់ចោទមិនយល់ ឬ មិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ ។ (ឆ) មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសមកលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។ ៤. នៅក្នុងករណីអនុវត្តនីតយិវិធីចំពោះអនីតិជន ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ ។ ៥. ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យតុលាការជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របច្បាប់ ។ ៦. នៅពេលជនណាម្នាក់ត្រូវបានប្រកាសឲ្យជាប់ពិរុទ្ធបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមក ការប្រកាសឲ្យជាប់ពិរុទ្ធនេះត្រូវបានបដិសេធ ឬត្រូវបានលើកលែងដោយអង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់តុលាការ ជនដែលរងគ្រោះដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់បង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេលវេលាបណ្តាលមកពីជននោះទាំងស្រុង ឬផ្នែក។ ៧.

៤. ជនជាប់ចោទនីមួយៗនៅចំពោះមុខតុលាការនេះមានសិទ្ធទទួលបានពេលវេលា និងមធ្យោបាយស្មើគ្នាសម្រាប់រៀបចំការពារខ្លួន[3]។ បន្ថែមពីលើនេះ ពួកគេក៏មានសិទ្ធិពិនិត្យភស្តុតាងប្រឆាំងនឹងពួកគេ និងទទួលបាននូវការចូលរួម និងពិនិត្យភស្តុតាងក្នុងនាមខ្លួននៅក្រោមលក្ខខណ្ឌដូចគ្នានឹងភស្តុតាងប្រឆាំងនឹងពួកគេដែរ[4] ។ ការធានាទាំងនេះ គឺជាការធានាអប្បបរិមា និងផ្អែកលើមាត្រា ១៤ នៃអនុសញ្ញា ICCPR[5] ។ វាជាភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីការពារសិទ្ធិនេះ និងធានាថា ការជំនុំជម្រះគឺប្រព្រឹត្តទៅដោយត្រឹមត្រូវ និងឆាប់រហ័ស និងប្រព្រឹត្តទៅដោយការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និង ការពារជនរងគ្រោះ និងសាក្សី[6] ។ ជាពិសេស ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅដោយសេរី[7] ។

៥. ច្បាប់បង្កើត អវតក ចែងបន្ថែមទៀតថា ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយ

---

គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើសដែលត្រូវផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនិតីវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ ។ មាត្រា១៥ ចែងថា: គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខនខានណាមួយ ដែលមិនបានចាត់ជាបទល្មើស ព្រហ្មទណ្ឌស្របតាមច្បាប់ជាតិនោះឡើយ ។ ដូចគ្នានេះមិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេល ប្រព្រឹត្តបទល្មើសឡើយ ។ ប្រសិនបើក្រោពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឲ្យមានការដាក់ស្រាលជាងមុន ជននោះត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។ ២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសជនណាម្នាក់ចំពោះអំពី ឬ អំពើអកម្មណាមួយ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសមាគមន៍នៃប្រជាជាតិ ។

[3] មាត្រា ៣៥(ខ)ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់បង្កើត អវតក”) ។

[4] មាត្រា ៣៥(ង)ថ្មី នៃច្បាប់បង្កើត អវតក ។

[5] មាត្រា ៣៥ ថ្មី នៃច្បាប់បង្កើត អវតក ។

[6] មាត្រា ៣៥ ថ្មី នៃច្បាប់បង្កើត អវតក ។

[7] វិធាន ៨៥ នៃវិធានផ្ទៃក្នុង ។

បទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ[8] ។

III. **ឧទ្ទិករណ៍**

ក. **ពេលវេលាបន្ថែមដើម្បីរៀបចំការសួរដេញដោលសាក្សីដែលសេសសល់ គឺចាំបាច់ បើពិចារណាពីកាលកំណត់ពេលវេលាសវនាការ និងលាតត្រដាងនាពេលថ្មីៗនេះ**

*(i) ការកំណត់ពេលវេលាការជំនុំជម្រះ និងការផ្លាស់ប្តូរលំដាប់រៀងសាក្សី*

៦. នៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តីត្រូវបានជូនដំណឹងពីការជ្រើសរើសសាក្សីសម្រាប់ស២១[9]។ នៅថ្ងៃទី២៣ និង២៤ ខែមីនា ឆ្នាំ២០១៦ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូង ឱ្យចាប់ផ្តើមស្តាប់ភស្តុតាងទាក់ទងទៅនឹងស២១ បន្ទាប់ពីការស្តាប់ភស្តុតាងទាក់ទងទៅនឹងអូរកន្សែង និងភ្នំក្រោល ត្រូវបញ្ចប់ និងនៅក្រោយការឈប់សំរាកថ្ងៃបុណ្យចូលឆ្នាំខ្មែរតែប៉ុណ្ណោះ[10]។ មេធាវីការពារក្តីក៏បានស្នើសុំពេលវេលាបន្ថែមដើម្បីសួរដេញដោលសាក្សី 2-TCW-916[11]។ សំណើនេះត្រូវបានអនុញ្ញាតនៅថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៦[12]។ ខណៈដែលជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់មេធាវីការពារក្តីសុំពន្យារពេលស្តាប់សក្ខីកម្មសាក្សី 2-TCW-916 រហូតដល់ដំណាក់ផ្នែកសវនាការទាក់ទងទៅនឹងការបោសសំអាតផ្ទៃក្នុង តែជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សក្ខីកម្មរបស់គាត់នឹងត្រូវស្តាប់នៅដំណាក់ផ្នែកសវនាការទាក់ទងទៅនឹងស២១[13]។

---

[8] មាត្រា ៣៣ ថ្មី នៃច្បាប់បង្កើត អវតក ។

[9] សារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ទៅកាន់ភាគី, "ស២១ ការបែងចែកពេលវេលាសម្រាប់សាក្សី 2-TCE-88 និងការកំណត់ពេលវេលាសម្រាប់សប្តាហ៍នៃថ្ងៃទី២១ ដល់២៤ ខែមីនា ឆ្នាំ២០១៦", ៧ ខែ មីនា ២០១៦ ។

[10] សារអេឡិចត្រូនិកពីមេធាវីការពារក្តី នួន ជា ទៅកាន់ភាគី កម្មវត្ថុ "ការកំណត់ពេលវេលាពីថ្ងៃទី២៨ ខែមីនា" ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ។ ប្រតិចារិតសវនាការថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ នៅ ១៥.២៨.៥៦ ។

[11] ប្រតិចារិកសវនាការ សំណុំរឿង ០០២/០២ ថ្ងៃទី ៣៩៣ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ នៅ 14:31: 06។

[12] សារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ទៅកាន់ភាគី កម្មវត្ថុ "ការកំណត់បពេលវេលា១៨-២៨ ខែមេសា ឆ្នាំ២០១៦" ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ។

[13] សារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ទៅកាន់ភាគី កម្មវត្ថុ "ការកំណត់បពេលវេលា១៨-២៨ ខែមេសា ឆ្នាំ២០១៦" ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ។

៧. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីថា សាក្សីមួយចំនួននឹងត្រូវស្តាប់សក្ខីកម្មក្នុងអំឡុងពេលសប្តាហ៍ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦[14]។ សារអេឡិចត្រូនិកនេះក៏បានចង្អុលបង្ហាញថា កាលកំណត់ពេលរបស់សាក្សីស២១ នៅក្រោយថ្ងៃចូលឆ្នាំខ្មែរ នឹងត្រូវផ្សព្វផ្សាយ "ឲ្យបានឆាប់ តាមដែលអាចធ្វើបាន"។ ជាលទ្ធផលពុំមានការឈប់សំរាកឡើយ លើកលែងតែការសម្រាកផ្លូវការរបស់តុលាការរវាងការស្តាប់ភស្តុតាងទាក់ទងទៅនឹងអ្នករកឡ្វេង និងភ្នំក្រោល និងស២១ ប៉ុណ្ណោះ។

៨. លំដាប់រៀងសាក្សីស២១ ត្រូវបានប្រគល់ជូនភាគីជាលើកដំបូងនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦[15]។ ការកំណត់ពេលដូចតទៅ: ថ្ងៃទី១៨ ខែមេសា សម្រាប់ ជុំ ម៉ី, ថ្ងៃទី១៩ ខែមេសា សម្រាប់ តយ តេង, ថ្ងៃទី២០ ខែមេសា សម្រាប់ ញ៉ែម អេន, ថ្ងៃទី២១ ខែមេសា សម្រាប់ ឡាច មាន, ថ្ងៃទី២៥ ខែមេសា សម្រាប់ ប្រាក់ ខាន់, ថ្ងៃទី២៦ ខែមេសា សម្រាប់សាក្សី 2-TCW-931, ថ្ងៃទី២៧ ខែមេសា សម្រាប់សាក្សី 2-TCW-808, ថ្ងៃទី២៨ ខែមេសា សម្រាប់សាក្សី 2-TCW-906 (ត្រូវបន្តដល់ថ្ងៃទី២ ខែឧសភា)។ ដូច្នេះការរៀបចំរបស់មេធាវីការពារក្តីត្រូវផ្អែកលើមូលដ្ឋាននៃការកំណត់ពេលនេះ និងក្នុងអំឡុងពេលនៃការឈប់សម្រាកថ្ងៃចូលឆ្នាំខ្មែរដែរ សម្រាប់សាក្សីដែលចូលបង្ហាញខ្លួនសម្រាប់សប្តាហ៍ថ្ងៃទី១៨-២១ ខែមេសានេះ។

៩. នៅថ្ងៃទី១៨ ខែមេសា ភាគីត្រូវបានជូនដំណឹងនៅក្នុងតុលាការថា សាក្សី តយ តេង មិនអាចស្តាប់សក្ខីកម្មបាន ហើយនឹងស្តាប់សក្ខីកម្មរបស់សាក្សី 2-TCW-919 នៅមុនការគ្រោងទុកជំនួសវិញ ដោយចាប់ផ្តើមនៅថ្ងៃទី១៩ ខែមេសា ។ សាក្សី តយ តេង ត្រូវបានកំណត់ពេលឡើង វិញ តែកាលបរិច្ឆេទមិនដឹងនៅឡើយ[16] ។ នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦

---

[14] សារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ទៅកាន់ភាគី កម្មវត្ថុ "ការកំណត់ពេលវេលា: សប្តាហ៍ចាប់ពីថ្ងៃទី៤ ខែមេសា ២០១៦" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ។

[15] សារអេឡិចត្រូនិកពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ទៅកាន់ភាគី កម្មវត្ថុ "ការកំណត់បពេលវេលា១៨-២៨ ខែមេសា ឆ្នាំ២០១៦" ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ។

[16] ប្រតិចារិកថ្ងៃសវនាការទី៣៩៨ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ នៅ ១៣.៣៥.១៤ ទំព័រ ៤៩ ។

មេធាវីការពារក្ដីត្រូវបានជូនដំនឹងថា សាក្សី តយ តេង នឹងផ្ដល់សក្ខីកម្មនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦[17] ។

១០. ការផ្លាស់ប្ដូរលំដាប់រៀងសាក្សី ព្រមទាំងភាពមិនប្រាកដទាក់ទងទៅនឹងលំដាប់រៀងសាក្សី មានផលប៉ះពាល់ជាអវិជ្ជមានលើការរៀបចំរបស់មេធាវីការពារក្ដី។ សមាជិកក្រុមចាត់ចែងការរៀបចំរបស់ពួកគេដោយផ្អែកលើការកំណត់ពេល ដែលផ្ដល់ដោយអង្គជំនុំជម្រះសាលាដំបូង ។ ពិចារណាពីធនធានកម្រិត និងចំនួននៃការរៀបចំសវនាការតម្រូវ (សូមមើលកថាខណ្ឌខាងក្រោម ១២ ដល់ ២២ សម្រាប់ព័ត៏មានលំអិត) មេធាវីការពារក្ដីមិនអាចកំណត់ការរៀបចំរបស់ខ្លួនសម្រាប់សាក្សីម្នាក់ រហូតដល់ពីរថ្ងៃបីថ្ងៃនៅមុនគាត់ចូលខ្លួនផ្ដល់សក្ខីកម្មឡើយ។ ការផ្លាស់ប្ដូរលំដាប់រៀងសាក្សី តម្រូវការកំណត់អទិភាព និងការរៀបចំសារជាថ្មី ហើយនៅពេលសាក្សីម្នាក់ត្រូវបានកោះហៅឲ្យចូលខ្លួនមុនការគ្រោងទុក ការរៀបចំសម្រាប់សាក្សីនេះអាចជាមិនពេញលេញ ។

១១. ចាប់តាំងពីការឈប់សម្រាកក្នុងថ្ងៃចូលឆ្នាំខ្មែរ សវនាការបានដំណើរការបួនថ្ងៃក្នុងមួយសប្ដាហ៍។ បើពិចារណាពីសារសំខាន់នៃផ្នែកសវនាការទាក់ទងទៅនឹងស២១ ព្រមទាំងអង្គហេតុដែលថា បញ្ហាជាច្រើនដែលត្រូវបានពិភាក្សាដោយសាក្សីនីមួយៗ ក៏ពាក់ព័ន្ធនឹងការរៀបចំសាក្សីផ្សេងៗទៀតដែរ (សូមមើលកថាខណ្ឌ ១៨ ដល់ ២២ ខាងក្រោមសម្រាប់ព័ត៏មានលំអិត) ដូច្នេះវាចាំបាច់សម្រាប់សមាជិកក្រុមការពារក្ដីយ៉ាងហោចណាស់ក៏ម្នាក់ដែរ ត្រូវមានវត្តមាន នៅតុលាការ ហើយសមាជិកក្រុមការពារក្ដីម្នាក់ទៀតត្រូវស្ដាប់/ពិនិត្យឡើងវិញនូវកិច្ចដំណើរការនីតិវិធី។ នេះគឺជាមូលហេតុដែលពេលវេលាបន្ថែម គឺចាំបាច់សម្រាប់ការរៀបចំសួរដេញដោលសាក្សីស២១ ដែលនៅសេសសល់ ។

## *(ii) ឯកសារថ្មីបានបន្ថែមទៅក្នុងសំណុំរឿង*

## ក. <u>បញ្ជីរបស់ កសចស</u>

១២. នៅថ្ងៃទី៥ ខែ មេសា ឆ្នាំ ២០១៦ ភាគីត្រូវបានជូនដំណឹងថា កសចស ក្នុងរយៈពេល២ឆ្នាំបានកំពុងធ្វើបញ្ជីបច្ចុប្បន្នមួយស្ដីពីអ្នកទោសដែលបានជាប់ឃុំនៅ២១។ បញ្ជីនេះមានឈ្មោះអ្នក

---

[17] ប្រតិចារិកសំណុំរឿង ០០២/០២ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៦ ១៦.០៣.០៥។

ទោសចំនួន ១៥.១០១ នាក់-ឬ ២.៨២៨នាក់ ច្រើនជាងបញ្ជីអ្នកទោសដែលបានរៀបចំដោយការិយាល័យសហព្រះរាជអាជ្ញា[18]។ អនុលោមតាម កសចស បានពិនិត្យ ១៣.៣៨៣ ឯកសាររួមទាំងបញ្ជីអ្នកទោសចូល (prisoner entry logs) ប្រវត្តិរូប សៀវភៅបញ្ជី បុគ្គលិកស២១ បញ្ជីសួរចម្លើយ និង សៀវភៅបញ្ជីសម្លាប់[19]។ ប៉ុន្តែបញ្ជីឯកសារដែលត្រូវបានប្រើប្រាស់ដោយ E393.3 កសចស មានតែ៨៧១ ឯកសារប៉ុណ្ណោះ ។

១៣. មេធាវីការពារក្តីជំទាស់យ៉ាងខ្លាំងខ្លាពីភាពត្រឹមត្រូវ និង ភាពអាចទុកចិត្តបាននៃបញ្ជីរបស់ កសចស។ ឧទាហរណ៍ចំពោះការចូល(entry) ទាក់ទងទៅនឹង ទុយ តេង បញ្ជីរបស់ កសចស ចង្អុលបង្ហាញថា គាត់ត្រូវបានសម្លាប់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧ ។ ប៉ុន្តែឯកសារដែល កសចស សំអាងដើម្បីគាំទ្រការអះអាងនេះ មិនបានយោងទៅលើកាលបរិច្ឆេទនៃការសម្លាប់ឡើយ[20]។ ដើម្បីជំទាស់ទៅនឹងបញ្ជីរបស់ កសចស មេធាវីការពារក្តីត្រូវពិនិត្យថ្ងៃចូល នីមួយៗ ក្នុងចំណោមថ្ងៃចូល ១៥ ១០១ ពិនិត្យឯកសារទាំងអស់ និងវាយតម្លៃថា តើឯកសារទាំងនេះ ពិតជានិយាយ ដូចអ្វីដែល កសចស និយាយដែរ ឬយ៉ាងណា។ មេធាវីការពារក្តីត្រូវការវិភាគ ភាពដើមនៃបញ្ជីនេះ-ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ DC-Cam និងធ្វើការស្រាវជ្រាវ ទាក់ទងទៅនឹងការបង្កើត ការទុកដាក់ និងខ្សែរសង្វាក់នៃការគ្រប់គ្រងបញ្ជីនេះ ។ ដោយសារ ឯកសារមួយភាគធំដែល កសចស ពឹងផ្អែក មិនទាន់បកប្រែចូលជាភាសាអង់គ្លេស ឬ បារាំង ការវិភាគជួបការលំបាកដោយសារចំនួនកម្រិតនៃអ្នកនិយាយភាសាខ្មែរក្នុងក្រុម និងបន្ទុកកិច្ចការបច្ចុប្បន្នរបស់ពួកគេ។ ជាចុងក្រោយមេធាវីការពារក្តីក៏ត្រូវស្នើសុំដាក់បញ្ចូលទៅក្នុងសំណុំរឿងនៃឯកសារទាំងនេះ ដើម្បីអាចលើកមកសំអាងនៅពេលជំទាស់បញ្ជី កសចស និងយោងវាក្នុងអំឡុងពេលសួរដេញដោលសាក្សី ។

---

[18] E342 "បញ្ជីអ្នកទោស ស២១" ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១២។

[19] E393.1"បញ្ជីអ្នកទោស ស២១ របស់ កសចស" ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦។

[20] E393.2 បញ្ជីអ្នកទោសដែលរៀបរៀងដោយកសចស ថ្ងៃចូល 6586 ERN 01222588 យោងចំពោះ EN/844 ហើយ ឯកសារ D06292 ។

១៤. ដោយសារ កសចស ខកខានមិនបានបង្ហាញបង្ហាញចំនួនសារុបនៃឯកសារដែលខ្លួនបានសំអាងនៅក្នុងបញ្ជីឯកសារដែលបានប្រើប្រាស់[21] ហើយក៏បានខកខានមិនបានប្រើប្រាស់លេខ E3 នៅក្នុងសំណុំរឿង០០២ សម្រាប់ឯកសារ (ជាជំនួសបានប្រើប្រាស់ប្រព័ន្ធបង់លេខរបស់ DC-Cam ឬ ទួលស្លែង) នេះគឺជាកិច្ចការត្រូវប្រើប្រាស់ពេលវេលាច្រើន។ ដោយគ្រាន់តែកំណត់អត្តសញ្ញាណ និង ទាញយកឯកសារ វាប្រើពេលអស់ច្រើនថ្ងៃទៅហើយ។ បើទោះបីមេធាវីការពារក្តីពិនិត្យតែដប់ម្តៃលើថ្ងៃចូល ដើម្បីបង្ហាញពីភាពមិនអាចទុកចិត្តបានរបស់បញ្ជី កសចស ក៏ប្រើពេលជាច្រើនថ្ងៃដែរ។ មេធាវីការពារក្តីយល់ឃើញថា ខ្លួនត្រូវតែបានអនុញ្ញាតដំណើរការកិច្ចការនេះនៅមុនសក្ខីកម្មរបស់សាក្សី 2-TCW-816 ដោយសារគាត់ទទួលបន្ទុករៀបចំបញ្ជីអ្នកទោស ដែល កសចស បានពឹងផ្អែកដើម្បីបង្កើតបញ្ជីរបស់ខ្លួន ។

ខ. <u>ឯកសារថ្មីផ្សេងៗទៀត</u>

១៥. បន្ថែមពីលើនេះនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានស្នើសុំដាក់ក្នុងសំណុំរឿងនូវរូបថតនៃអ្នកទោសនៅមន្ទីរស២១ ចំនួន១៥៨៩ទំព័រ ដែលផ្តល់ដោយ DC-Cam[22]។ អត្ថបទបកប្រែភាសាអង់គ្លេសនៃបញ្ជីដែលពាក់ព័ន្ធជាមួយរូបថតទាំងនេះ ក៏ត្រូវបានជូនដំណឹងនៅថ្ងៃដដែល[23] ។ ភាពត្រឹមត្រូវរបស់ប្រភពដែលប្រើដោយ DC-Cam និងការវិភាគ-នៅពេលដែលអាចធ្វើបាន-នៃបុគ្គលនៅក្នុងរូបថត រួមទាំង cross-referencing ជាមួយបញ្ជី កសចស តម្រូវពេលវេលា និង ការខិតខំប្រឹងប្រែងជាច្រើន ។

១៦. ទីបញ្ចប់ទើបតែប៉ុន្មានថ្ងៃកន្លងទៅនេះ សហព្រះរាជអាជ្ញាបានដាក់បង្ហាញការកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី 2-TCW-931 និង 2TCW-816[24] ។ កំណត់ហេតុនៃការស្តាប់

---

[21] E393.3 "បញ្ជីអ្នកទោស ស២១ របស់ កសចស" ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦។

[22] E394.1 "បញ្ជីអ្នកទោស ស២១ របស់ កសចស" ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦។

[23] E3/9214 "មជ្ឈមណ្ឌលឯកសារកម្ពុជា, បញ្ជីឈ្មោះ និង រូបថតរបស់អ្នកទោស" ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៦។

[24] E319/46.2 "បញ្ជីឯកសារពីរដាក់បង្ហាញដោយ កសត" ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦។ E319/46.3.1 "កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី 2-TCW-816"ថ្ងៃទី ៦ កុម្ភៈ ឆ្នាំ២០១៥។ E319/46.3.2 "កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ប្រាក់ខន" ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ២០១៥។

ចម្លើយទាំងពីរនេះត្រូវតែពិនិត្យឡើងវិញ ហើយភស្តុតាងដែលបានវិភាគកន្លងមក អាចពិនិត្យឡើងវិញ អនុលោមតាមព័ត៌មានថ្មីដែលអាចមាន ។

១៧. មេធាវីការពារក្តីយល់ឃើញថា ឯកសារថ្មីទាំងនេះតម្រូវពេលវេលាបន្ថែម ដើម្បីពិនិត្យ វិភាគ និងជាចុងក្រោយប្រើប្រាស់ ឬជំទាស់ក្នុងអំឡុងពេលសួរដេញដោលសាក្សីរបស់ខ្លួន ។

*(iii)* ***ចំនួនឯកសារ***

១៨. ភាគី និង អង្គជំនុំជម្រះមិនអាចបដិសេធថា ស ២១ គឺជាគឺជាផ្នែកសំខាន់មួយនោះទេ។ ការរៀបចំសម្រាប់សាក្សីនីមួយៗតម្រូវឲ្យប្រើពេលវេលាច្រើនដំណាក់កាលក្នុងការឲ្យការរៀបចំមានលក្ខណៈទូលំទូលាយ។ សាក្សី 2-TCW-906, 2-TCW-816 និង 2-TCW-906 បានផ្តល់ចម្លើយមួយចំនួនជូន កសចស នៅក្នុងសំណុំរឿង ០០១ និងត្រូវបានលើកឡើងដោយស្ទើរតែគ្រប់សាក្សីទាំងអស់ទាក់ទងនឹងមន្ទីរស ២១ ដែលមានកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិក។ ឧទាហរណ៍ដូចជា ការស្វែងរកជាធម្មតានៅក្នុង Zylab សម្រាប់ឈ្មោះ និង នាមត្រកូលសាក្សី 2-TCW-906 មានលទ្ធផលរហូតដល់ ៣៦៤ ជាភាសាអង់គ្លេស និង សម្រាប់ 2-TCW-816 មានរហូតដល់ ១៩៣ គ្រាន់តែជាភាសាអង់គ្លេសតែមួយ។ ទាក់ទងនឹងសាក្សី 2-TCW-916 ចម្លើយនៅក្នុង Zylab គឺមានបញ្ហាបច្ចេកទេស និងមិនបង្ហាញលទ្ធផលលើចំនួនឯកសារដែលមាន។ ការស្វែងរកនេះមិនរាប់បញ្ចូលការប្រកបផ្សេងៗគ្នា ឬក៏កាស្វែងរកតែចំពោះនាមត្រកូលដែលត្រូវបានគេលើកឡើងនោះទេ។ បន្ថែមពីលើនោះទៅទៀតនោះ វាគួរឲ្យកត់សម្គាល់ថា ដោយសារតែមិនមានការប្រកបឈ្មោះខ្មែរ និង នាម ជាភាសាអង់គ្លេសដែលមានភាពស៊ីសង្វាក់គ្នា ការប្រកបមួយចំនួន និង ឈ្មោះហៅក្រៅ និងទីតាំងសម្រាប់សាក្សីមួយអាស្រ័យហេតុនេះហើយ វាតម្រូវឲ្យមានការស្វែងរកដដែលនៅក្នុងសំណុំរឿង។

១៩. បន្ថែមពីលើនេះទៀតនោះ កំណត់ហេតុស្តាប់ចម្លើយ បទសម្ភាសន៍ និង ប្រតិចារិករបស់បុគ្គលទាក់ទងនិង ស ២១ ដែលមិនបាននិយាយដោយសាក្សីទាំងនោះចាំបាច់ត្រូវតែពិនិត្យឡើងវិញ ដើម្បីប្រៀបធៀបប្រវត្តិនៃព្រឹត្តិការ។ សាក្សីសម្រាប់ ស២១ ដែលនៅសេសសល់ ក៏លើកឡើងនៅក្នុងឯកសាររាប់រយ ដូចជាបញ្ជីឈ្មោះអ្នកទោស ប្រវត្តិរូប របាយការណ៍ សៀវភៅប្រវត្តិសាស្ត្រ ភាពយន្តឯកសារ។ ជាចុងបញ្ចប់ ព្រឹត្តិការណ៍ទាក់ទងនឹងវគ្គផ្សេងទៀត

ជាពិសេសការបោសសម្អាតផ្ទៃក្នុង កងពល៧០៣ និងទំនាស់ជាមួយវៀតណាម ក៏មានភាព ពាក់ព័ន្ធនឹងមន្ទីរ ស២១ ខ្លាំងណាស់ដែរ។

២០. កាទទួលបានលទ្ធផលឯកសារដែលពាក់ព័ន្ធសម្រាប់សាក្សីស២១ដែលនៅសល់ប្រហែលជាមានរហូតដល់រាប់ពាន់ទំព័រឯណោះ។ ការជ្រើសរើស និងត្រួតពិនិត្យឯកសារទាំងនេះវាកម្រិតអប្បបរិមាក្នុងការរៀបចំសួរដេញដោល និងដូចដែលអង្គជំនុំជម្រះបានជ្រាបហើយថា គឺត្រូវការប្រើប្រាស់ពេលច្រើនណាស់។

២១. បន្ថែមពីលើនេះទៀត អង្គហេតុជាច្រើន នៅបន្ទាប់ពីសហព្រះរាជអាជ្ញាបានបង្កើតឡើង យើងខ្ញុំចាំបាច់ត្រួតពិនិត្យយ៉ាងហ្មត់ចត់។ ឧទាហរណ៍ នៅពេលដែលមើលទៅហាក់ដូចជាទស្សនៈទូទៅយល់ថា មានសាកសពចំនួន ៨៩៨៥ ត្រូវបានរកឃើញនៅជើងឯក តែមេធាវីការពារក្ដីនៅមិនអាចរកឃើញប្រភពច្បាស់លាស់សម្រាប់ចំនួននេះនៅឡើយទេ ហើយខ្លួនកំពុងតែបន្តការស្រាវជ្រាវបន្តទៅទៀតដើម្បីរកឯកសារដើម និង/ឬ ប្រភពព័ត៌មាននេះ។

២២. ជាងនេះទៅទៀតនោះ មេធាវីការពារក្ដី ត្រូវតែចាប់ផ្ដើមស្រាវជ្រាវជាសាធារណៈ ដើម្បីរកអត្តសញ្ញាណព័ត៌មានដែលពាក់ព័ន្ធ ដែលហាក់ដូចជាមិនត្រូវបានស៊ើបអង្កេតដោយ កសចស ឬក៏ កសព។ សារព័ត៌មាននៅខែ កុម្ភៈ ឆ្នាំ ២០១៦ និយាយយោងទៅលើការធ្វើកោសលវិច័យនៅជើងឯក ដែលនេះជាការធ្វើឡើងជាលើកដំបូង ហើយពិតជាត្រូវបានមើលឃើញថា ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសំណុំរឿងសម្រាប់គ្រប់ភាគីទាំងអស់ ហើយអង្គជំនុំជម្រះកំពុងតែធ្វើការក្នុងការទទួលបានរបាយការណ៍កោសលវិច័យនេះ[25]។ ការវិវត្តន៍ដូចនេះបង្ហាញថា ជាដំបូងពេលវេលាគ្រប់គ្រាន់គួរតែត្រូវបានផ្ដល់ដល់មេធាវីការពារក្ដីក្នុងការរៀបចំដើម្បីធានាថា គ្មានថ្មណាមិនត្រូវបានប៉ះឡើយ និងទីពីរ ភស្តុតាងដែលវិភាគកាលពីមុនត្រូវការត្រួតពិនិត្យនៅបន្ទាប់ពីលទ្ធផលនៃការពិនិត្យ។

២៣. សាក្សីបន្ថែមក៏អាចត្រូវការកោះហៅ ឬក៏សាក្សីដែលបានផ្ដល់សក្ខីកម្មរួចហើយ ដូចជា តយតេង អាចត្រូវបានកោះហៅមកជាថ្មីម្ដងទៀត។ ជាសំខាន់ចុងក្រោយនោះគឺឯកសារជាច្រើន

---

[25] ប្រតិចារិកសាវនាការសំណុំរឿង 00២/0២ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៦២ នៅ 11.39.37 ទំព័រ ៦៦ នៅ 13.36.44។

ដែលបានមកពីការស្រាវជ្រាវខាងលើនេះ អាចនឹងមិនត្រូវបានដាក់ក្នុងសំណុំរឿង ហើយ អាស្រ័យហេតុនេះហើយ សំណើតាមវិធាន ៨៧(៤) អាចត្រូវបានរៀបចំ និង ដាក់ជូន។

**ខ. ត្រូវការពេលវេលាបន្ថែមដើម្បីការពារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌**

២៤. នៅពេលដែលអង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការធានាថា ដំណើរការត្រូវប្រព្រឹត្តទៅដោយឆាប់ តែប្រការនេះមិនត្រូវធ្វើឡើងដោយរំលោភដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌នោះទេ។ មេធាវីការពារក្តីសូមលើកឡើងថា ការកោះហៅសាក្សី2-TCW-906 និង 2-TCW-816 និង 2-TCW-916 ដោយមិនអនុញ្ញាតឱ្យមេធាវីការពារក្តីរៀបចំដោយត្រឹមត្រូវ នឹងរំលោភដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានពេលវេលា និង លទ្ធភាពគ្រប់គ្រាន់ក្នុងការការពារក្តី និង ការដកយកសិទ្ធិរបស់គាត់ក្នុងការសួរដេញដោលសាក្សី។

***(i) សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្តី***

២៥. ដូចដែលបានលើកឡើងខាងលើ ជនជាប់ចោទម្នាក់ៗនៅចំពោះមុខសវនាការគឺតម្រូវឱ្យមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្តី[26]។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានបកស្រាយមាត្រា១៤ នៃ ICCPR ដែល ច្បាប់អវតក ផ្អែកទៅលើថា "ពេលវេលាគ្រប់គ្រាន់" គឺអាស្រ័យលើកាលៈទេសៈនៃសំណុំរឿងនីមួយៗ[27]។ ក្នុងនោះរួមមានភាពស្មុគស្មាញនៃសំណុំរឿង ការចូលមើលសំណុំរឿងរបស់ជនជាប់ចោទ ផ្តល់ពេលវេលាមានព្រំដែនកំណត់។ល។[28] គោលការណ៍ណែនាំជាមូលដ្ឋានគឺថា ជនជាប់ចោទត្រូវតែអាចរៀបចំដោយត្រឹមត្រូវក្នុងការការពារក្តីរបស់ខ្លួន គឺមានន័យថារៀបចំក្នុងការតទល់ជាមួយភស្តុតាង ការស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញា និងបង្ហាញ

---

[26] មាត្រា ៣៥ (ខ) ថ្មីច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ (ច្បាប់បង្កើត អវតក)។

[27] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ CCPR General Comment 32 (2007), para. 32។

[28] Albert and Le Compte v Belgium [1983] ECHR 1, para 41; Hibbert v Jamaica, HRC Communication 293/1988, UN Doc CCPR/C/45/D/293/1988 (1992), para 7.4; and Williams v Jamaica, HRC Communication 561/1993, UN Doc CCPR/C/59/D/561/1993 (1997), para 9.3។

សាក្សីរបស់មេធាវីការពារក្តី។ មេធាវីការពារក្តីសូមលើកឡើងថា នៅក្នុងកាលៈទេសៈសំណុំរឿងក្នុងពេលនេះ ខ្លួនមិនអាចធ្វើទៅរួចទេ បើគ្មានការផ្តល់ឱ្យនូវពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យភស្តុតាងនៅក្នុងកថាខណ្ឌ ១២ ដល់ ១៧ និងចាប់ផ្តើមការស្រាវជ្រាវដែលរៀបរាប់នៅក្នុងកថាខណ្ឌ ១៨ ដល់ ២២ ខាងលើ។

*(ii)* ***សិទ្ធិក្នុងការពិនិត្យសាក្សី***

២៦. បន្ថែមពីលើនេះ លោក នួន ជា មានសិទ្ធិក្នុងការពិនិត្យភស្តុតាងដែលប្រឆាំងនឹងគាត់[29]។ ទាំងអស់នេះរួមមានសិទ្ធិក្នុងការសួរដេញដោលសាក្សីរបស់សហព្រះរាជអាជ្ញា និងពិនិត្យសាក្សីរបស់មេធាវីការពារក្តីដែលប្រឆាំងនឹងគាត់[30] ហើយដែលជាសមាសភាពដ៏សំខាន់សម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌។ ខណៈដែលនៅ អវតក គ្មានការសួរដេញដោយខ្លួនឯងដូចនេះ គោលការណ៍ដែលបានលើកឡើងដូចនេះត្រូវបានអនុវត្ត។ ជាពិសេសដើមបណ្តឹងគួរតែមានឱកាសក្នុងការជំទាស់ទៅនឹងចម្លើយ ឬសក្ខីកម្មរបស់សាក្សីក្នុងអំឡុងពេលតទល់ ឬក៏សួរដេញដោល[31]។ ដើម្បីឱ្យមានប្រសិទ្ធិភាព សិទ្ធិនេះទាមទារឱ្យមានការផ្តល់ឱ្យពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការសួរដេញដោលសាក្សី។ ប្រសិនបើសំណើនេះមិនត្រូវបានផ្តល់ឱ្យ ហើយដំណើរការនៅតែបន្តដោយរបៀបនេះ នោះសិទ្ធិនេះគឺមានតែលើក្រដាស់តែប៉ុណ្ណោះ និងធ្វើឱ្យគ្មានប្រសិទ្ធិភាព អាស្រ័យហេតុនេះហើយសិទ្ធិនេះនឹងត្រូវបានរំលោភ។

*(iii)* ***សមភាពក្នុងការការពារក្តី***

២៧. គោលការសមភាពក្នុងការការពារក្តីត្រូវបានចែងនៅក្នុងមាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ដែលនិយាយថា ការធានានូវការជំនុំជម្រះក្តីដោយយុត្តិធម៌កម្រិតអប្បបរិមារបស់ជនជាប់ចោទត្រូវតែអនុវត្ត "ដោយស្មើគ្នា"។ គឺមានន័យថា "តុល្យភាពដ៏ត្រឹមត្រូវ" មួយត្រូវតែមានរវាងភាគី ហើយទាមទារឱ្យភាគីនិមួយៗត្រូវបានផ្តល់ឱ្យនូវឱកាសមួយសមរម្យក្នុងការ

---

[29] មាត្រា ៣៥ (ង) ថ្មីច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ (ច្បាប់បង្កើត អវតក)។

[30] *See e.g.* UN Human Rights Committee, CCPR General Comment 32 (2007), para 39; see also *KhuseynovaandButaeva v Tajikistan*, HRC Communications 1263/2004 and 1264/2004, UN Doc CCPR/C/94/D/1263–1264/2004 (2008), para 8.5 ។

[31] *See e.g. Bricmont v Belgium* [1989] ECHR 12, para 81. ។

ការពារក្តី នៅក្នុងលក្ខខណ្ឌ ដែលធ្វើឱ្យគូរប្រកួតរបស់ខ្លួនមានប្រៀបច្រើនជាង[32]។ នៅក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញាបានធ្វើការក្នុងសំណុំរឿង ០០១ និង បានរៀបចំរួចមកហើយសម្រាប់សាក្សីភាគច្រើន ដោយសារតែសាក្សីនៅសល់នេះបានផ្តល់សក្ខីកម្មរួចមកហើយនៅក្នុងសំណុំរឿង ០០១ ដែលមានចំនួន ៧៧ថ្ងៃ ហើយថា មេធាវីការពារក្តីនៅពេលនេះបង្ខំឱ្យចាប់ផ្តើមនូវទំហំការងារក្នុងរយៈពេលតែ១២ថ្ងៃ។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា បើទោះជាភស្តុតាងគឺវាទូទៅរវាងសំណុំរឿង ០០២/០១ និង ០០២/០២ក៏ដោយ ក៏ភាពដូចគ្នានេះមិនពន្លាតរហូតដល់ការរកឃើញ និងជាលទ្ធផល រាល់អង្គហេតុដែលបានមកពីសំណុំរឿង ០០២ ត្រូវតែថ្មី ដោយអនុវត្តដូចគ្នាទៅនឹងការរកឃើញពីសំណុំរឿង០០១[33]។ ប្រសិនបើមេធាវីការពារក្តីមិនត្រូវបានផ្តល់ឱ្យនូវពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យមើលឯកសារសម្រាប់សាក្សីដូចគ្នានេះ នោះអង្គជំនុំជម្រះនឹងដាក់មេធាវីការពារក្តីដោយមានប្រសិទ្ធិភាពនៅក្នុងស្ថានមួយដែលមិនស្មើនឹងសហព្រះរាជអជ្ញា អាស្រ័យហេតុនេះហើយវានឹងរំលោភដល់គោលការសំខាន់នេះ។ ដូចនេះការផ្តល់នូវពេលវេលានេះនឹងធានាដល់មានការពារនូវគោលការណ៍នេះ។

**គ. អង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការបង្គាប់ឱ្យផ្អាកសវនាការដើម្បីធានាឱ្យមានការកាត់ក្តីដោយយុត្តិធម៌**

២៨. មេធាវីការពារក្តីសូមគាំទ្រយ៉ាងកក់ក្តៅនៅក្នុងដំណើរការក្នុងពេលបច្ចុប្បន្ននេះប្រកបដោយប្រសិទ្ធិភាព និង ឆាប់រហ័ស។ មេធាវីការពារក្តីបានប្រឹងប្រែងក្នុងការការពារផលប្រយោជន៍របស់លោក នួន ជា និងការពារក្តីទៅតាមពេលកាលវិភាគរបស់អង្គជំនុំជម្រះ។ តែទោះជា

---

[32] *Werner v Austria* [1997] ECHR 92, para 63; Coëme and *Others v Belgium* [2000] ECHR 250, para 102; *G. B. v France* [2001] ECHR 564, para 58។

[33] **E301/9/1/1/3** "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ណ និង វិសាលភាពនៃសំណុំរឿង ០០២/០២" ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៤ កថាខណ្ឌ ៨៥។ សូមមើលបន្ថែមទៀត **E314/6** "បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និង ចៅក្រម យូរខត្តា" ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ១២២។

យ៉ាងណាក៏ដោយ ដូចដែលបានលើកឡើងខាងលើថា ការពន្លឿនដំណើរការមិនត្រូវបានប្រើក្នុងករណីដែលរំលោភសិទ្ធិរបស់ជនជាប់ចោទនោះទេ។

២៩. គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានគិតថា តុលាការមានកាតព្វកិច្ចផ្តល់ជូននូវសំណើសមរម្យសម្រាប់ការផ្អាកសវនាការ ជាពិសេសនៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់លើបទល្មើសធ្ងន់ធ្ងរ ហើយពេលវេលាបន្ថែមសម្រាប់ការរៀបចំការការពារក្តីគឺចាំបាច់[34]។ ការផ្អាកដំណើការ ដើម្បីអនុញ្ញាតឱ្យមេធាវីការពារក្តីត្រួតពិនិត្យឯកសារជាក់លាក់ និងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំសម្រាប់សវនាការ គឺជាការអនុវត្តជាទូទៅនៅក្នុងតុលាការមិនអចិន្ត្រៃយ៍ផ្សេងទៀត[35] និងនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ[36]។

៣០. បន្ថែមពីលើនេះ មេធាវីការពារក្តីសូមលើកឡើងថា ការផ្តល់តាមសំណើនេះវានឹងមិនមានផលប៉ះពាល់ដល់រយៈពេលដំណើរការនោះទេ តែការអនុញ្ញាតដល់មេធាវីការពារក្តីក្នុងការពិនិត្យត្រឹមត្រូវលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង និងភស្តុតាងថ្មីទៀតនៅចំពោះមុខសាក្សីសម្រាប់ស២១ នៅសេសសល់ដែលនឹងត្រូវមកផ្តល់សក្ខីកម្ម គឺផ្ទុយមកវិញអង្គជំនុំជម្រះនឹងធានាឱ្យមានការរៀបចំល្អប្រសើរជាងនេះសម្រាប់ការការពារក្តី ដែលធ្វើឱ្យមានការសួរដេញដោលសាក្សីប្រកបដោយប្រសិទ្ធិភាព។ ជាងនេះទៅទៀត វានឹងធានាថា រាល់ឯកសារពាក់ព័ន្ធនិងការអះអាងត្រូវបានសួរទៅកាន់សាក្សី ដែលជួយឱ្យមានការកម្រិតក្នុងការកោះហៅជាថ្មីឬក៏កោះហៅសាក្សីថ្មី។ សំខាន់ទៀតនោះ វានឹងជួយដល់អង្គជំនុំជម្រះផងដែរក្នុងការស្វែងរកការពិត ដែលវាបានផ្តល់នូវរូបភាពមួយពេញលេញអំពីភស្តុតាងពាក់ព័ន្ធ ដោយសារបានជំទាស់ទៅនឹងទស្សនៈតែម្ខាងរបស់ កសព។

---

[34] HRC, CCPR General Comment 32 (2007), para 32; HRC, Kurbanov v. Tajikistan (2003), para 7.3។

[35] *See e.g.* ICTY, *Prosecutor v. Karadžić*, IT-95-5/18-T, Decision on Accused's Motion for Suspension of Proceedings, 18 Aug 2010; *Prosecutor v. Stanišić & Simatović*, IT-03-69-T, Decision on Stanisic Defence Motion for Adjournment of Proceedings, 25 Jan 2011។

[36] តុលាកាព្រហ្មទណ្ឌអន្តរជាតិ, Prosecutor v. Ruto & Sang, Decision No. ICC-01/09-01/11-642, Decision Concerning the Start Date of Trial, 8 Mar 2013; Prosecutor v. Muthaura & Kenyatta, សេចក្តីសម្រេចលេខ ICC-01/09-02/11-677, Order Concerning the Start of the Trial, ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៣; Prosecutor v. Gbagbo, Decision No. ICC-02/11-01/11-152-Red, Decision on the 'Requête de la Défense en report de l'audience de confirmation des charges prévue le 18 Juin 2012', ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២។

៣១. មេធាវីការពារក្តីសូមលើកឡើងថា អង្គជំនុំជម្រះត្រូវតែបង្គាប់ឲ្យមានផ្អាកក្នុងរយៈពេលខ្លីមួយ ដើម្បីផ្តល់ជូននូវការការពារដោយពេញលេញដល់សិទ្ធិជាមូលដ្ឋានរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដ៏យុត្តិធម៌។ មេធាវីការពារក្តី សូមដាក់ជូនដោយគោរពថា នេះគឺជាជម្រើសតែមួយគត់ក្នុងការការពារដល់សិទ្ធិរបស់ នួន ជា នៅក្នុងសំណុំរឿងនេះ ហើយថា ការខកខានធ្វើដូចនេះនឹងជាការរំលោភលើកាតព្វកិច្ចរបស់ខ្លួនដែលចែងនៅក្នុងមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក និង វិធាន ៨៥ នៃវិធានផ្ទៃក្នុង។

## IV. សំណើរសុំ

៣២. សម្រាប់ហេតុផលដូចដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះ

(ក) ផ្តល់ជូននូវពេលវេលាបន្ថែមក្នុងការរៀបចំសម្រាប់សាក្សី ស២១ ដែលនៅសេសសល់ និងបង្គាប់ថា សវនាការត្រូវបានផ្អាកចំនួន ៤ សប្តាហ៍នៅបន្ទាប់ពីសក្ខីកម្មសាក្សី of 2-TCW-808។ ឬក៏ជម្រើសផ្សេងទៀត

(ខ) ត្រូវឲ្យមានការប្រជុំរៀបចំសវនាការ ដូចដែលបានចែងនៅក្នុងវិធាន ៧៩ (៧) នៃវិធានផ្ទៃក្នុង ដើម្បីពិភាក្សាលើកាលវិភាគសវនាការ និង ការរៀបចំសាក្សី និង ការកំណត់នូវវិធានការដែលនឹងអាចសមរម្យសម្រាប់គ្រប់ភាគីទាំងអស់។ ឬក៏ជម្រើសផ្សេងទៀត

(គ) បង្គាប់ថា សាក្សី2-TCW-906, 2-TCW-816 និង 2-TCW-916 និងត្រូវតែសួរដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្តដោយមេធាវីការពារក្តី រហូតដល់ពេលវេលាគ្រប់គ្រាន់ត្រូវបានប្រើប្រាស់សម្រាប់មេធាវីការពារក្តី ដើម្បីចាប់ផ្តើមការរៀបចំចាំបាច់ ដោយមិនមានដំណើរការសវនាការកើតមានឡើង។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE